ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០៣-៦-២០១៣ -ព្រះរាជក្រម នស/រកម/០៦១៣/០០៦ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ៥១៧០

០៣-៦-២០១៣ -ព្រះរាជក្រម នស/រកម/០៦១៣/០០៧ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ៥១៨២


### ២~ព្រះរាជក្រឹត្យ


២០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២១ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ឹង ជុនហួរ** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥១៩១

២០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២២ ស្តីពី ការតែងតាំងឯកឧត្តម **ទេប តែម** ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានឋានៈស្មើ អគ្គនាយក ៥១៩២

២០-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ សប្បុរសជនជាតិ និងអន្តរជាតិ ចំនួន ២១ រូប ៥១៩៣

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងសប្បុរសជន ចំនួន ៧៩ អង្គ/រូប ៥១៩៤

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២៦ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០២ រូបនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៥១៩៦

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ ឧកញ៉ា **ហាន់ ឃៀង** ៥១៩៧

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២៨ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកស្រីឧត្តមសេនីយ៍ត្រី **សុខ ចន្ទីរ៉ា** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥១៩៨

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥២៩ ស្តីពី ការកាត់ផ្ទៃដី ទំហំ ១.២៧៣ ហិកតា ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៣ ៥១៩៩

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ កងទ័ពប្រជាជនវៀតណាម ចំនួន ០៦ រូប ៥២០០

២២-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣១ ស្តីពី ការតែងតាំងឯកឧត្តម **ឡាយ ម៉ាន់** ជាទីប្រឹក្សាលោកជំទាវ **ឃួន សុដារី** អនុប្រធានទី ២ នៃរដ្ឋសភា មានឋានៈស្មើរដ្ឋលេខាធិការ ៥២០១

២៣-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ ព្រះអនុគណខណ្ឌពោធិ៍សែនជ័យ និងជាព្រះចៅអធិការវត្តជម្ពូវ័ន និងគណៈកម្មការ អាចារ្យវត្ត ព្រមទាំងសប្បុរសជន ចំនួន ០៦ អង្គ/រូប ៥២០២

២៣-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៣ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូនឯកឧត្តមឧត្តមសេនីយ៍ត្រី **គឹម សុខុន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥២០៣

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ លោកជំទាវ **ទេព បុប្ផា ប្រសិទ្ធ** ៥២០៤

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **មូន ឆាន់ស៊ីក** (MOON CHANSHIK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្តជនបុក សាធារណរដ្ឋកូរ៉េ ៥២០៥

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ស៊ឿ ហុង** (XUE HONG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តលៀវនីង សាធារណរដ្ឋប្រជាមានិតចិន ៥២០៦

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោកស្រី **វ៉ុង លីវ៉ា** (WONG LEE WA) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ៥២០៧

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាង បៃហ្វុង** (YANG BAIFENG) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហីឡុងជាំង សាធារណរដ្ឋប្រជាមានិតចិន ៥២០៨

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៣៩ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យំា គាយី សាយមិន** (YUM KA YEE SIMON) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន ៥២០៩

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៤០ ស្ដីពី ការដំឡើងឋានន្តរស័ក្ដិ ថ្នាក់ ឧត្ដមសេនីយ៍ទោ ជូនលោកឧត្ដមសេនីយ៍ត្រី **សម ខណ្ឌខីរៈ** នាយនគរបាលថ្នាក់ឧត្ដមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥២១០

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៤១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ អ្នកស្ម័គ្រចិត្ត និង សប្បុរសជន ចំនួន ៥០ រូប ៥២១១

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៤២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៥ រូប ៥២១៣

២៥-៥-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៥១៣/៥៤៣ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ លោកជំទាវ **ជា ខេង ស៊ុយ សែម** ៥២១៤

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៥៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៥៧២,៧០ ហិកតា នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្គោលហ្វៃសិន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ និងការផ្ដល់សិទ្ធិលើក្បាលដី ៥២១៥

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៥៥ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៣៦៨,៨៥ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣២២ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២១៨

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៥៦ អនក្រ.បក ស្ដីពី ការកាត់ដីទំហំ ៤២៩,៤៧ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣៦ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២២១

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៥៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៤៨៣,៨៩ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤១៤ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២២៤

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៥៨ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣៩៦,៩២ ហិកតា នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្គោល ហ្វៃសិន និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ ប្រឡាយ) និងការផ្តល់សិទ្ធិ លើក្បាលដី ៥២២៧

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៥៩ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ១.៨៥៤,៦៤ ហិកតា នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្គោល ហ្វៃសិន និងកាត់ចេញ ពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយ ចំណែកជាដីសាធារណៈរបស់រដ្ឋ និងការផ្តល់សិទ្ធិលើក្បាលដី ៥២៣០

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៦០ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៩៦៦,២០ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣១២ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២៣៣

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៦១ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣០៨,៤៤ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣៥ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២៣៦

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៦២ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៥៥១,៧៣ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៣៧ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២៣៩

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៦៣ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣១៥,៣៩ ហិកតា នៅស្រុករមាសហែក ខេត្តស្វាយរៀង ចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៥ គ្រួសារ និង រក្សាទុកមួយចំណែកទុកជាដីសាធារណៈរបស់រដ្ឋ ៥២៤២

២៧-៥-២០១៣ -អនុក្រឹត្យលេខ ២៦៤ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៣.៤៨៩ ហិកតា នៅស្រុក មេមត់ ខេត្តកំពង់ចាម ចេញពីដីព្រៃសម្បទានរបស់ សាម លីញ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៩៥៨ គ្រួសារ និងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី ៥២៤៥

២៧-៣-២០១៣ -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥២៤៨

២៧-៣-២០១៣ -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥២៥០

២៧-៣-២០១៣ -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥២៥៣

២៧-៣-២០១៣ -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពី ការលុបឈ្មោះ នាយអារុំធបាត្ត ៥២៥៥

២៧-៣-២០១៣ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥២៥៧

២៧-៣-២០១៣ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥២៥៨

## III~ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៦-៥-២០១៣ -ប្រកាសលេខ ៤៣០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុង-អ៊ូ ខេមបូ អេនធើប្រាយ បង្កើតរោងចក្រ ផលិតគ្រឿងសង្ហារឹម (ផ្ទះបាយ ការិយាល័យ) និងផ្សេងៗ ទៀត ៥២៨០

១៦-៥-២០១៣ -ប្រកាសលេខ ៤៣១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីដាប់បែលយូ ខេអេជ ហ្គាមេន (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិត សម្លៀកបំពាក់ ៥២៨៤

១៦-៥-២០១៣ -ប្រកាសលេខ ៤៣២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌីអេហ្វ ហ្វេសិន អ៊ីភែរីល (ខេមបូឌា) បង្កើតរោងចក្រ ផលិត សម្លៀកបំពាក់ ៥២៨៨

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៦

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្ដីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ៣ថ្មី.- និយមន័យនៃពាក្យបច្ចេកទេស**

ទោះបីមានបទប្បញ្ញត្តិច្បាប់ផ្សេងទៀតក៏ដោយពាក្យថា ៖

ក- ការសម្អាតប្រាក់ គឺជា ៖

១- ការបំប្លែងឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសក្នុងគោលបំណងបិទបាំងឬក្លែងប្រភពដើម មិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន ។

២- ការបិទបាំងឬការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬកម្មសិទ្ធិឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៣- ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស ។

៤- ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយនិងជំរុញឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់ស្របតាមមាត្រា៣ នៃច្បាប់នេះ ។

ខ- ផលនៃបទល្មើស គឺជាទ្រព្យសម្បត្តិណាដែលបានឬទទួលដោយផ្ទាល់ឬដោយប្រយោលតាមរយៈការប្រព្រឹត្តបទល្មើសឧក្រិដ្ឋឬបទល្មើសមជ្ឈិម ។

គ- ទ្រព្យសម្បត្តិ គឺជាទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យឬអចលនទ្រព្យរូបិយឬអរូបិយ និងឯកសារ ឬឧបករណ៍គតិយុត្ត ដែលជាភស្តុតាងនៃកម្មសិទ្ធិឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ ។

ទ្រព្យសម្បត្តិរួមបញ្ចូលឧបករណ៍និងផលបានមកពីការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងបទល្មើសធ្ងន់ធ្ងរផ្សេងៗ ។ ទ្រព្យសម្បត្តិរួមបញ្ចូលទ្រព្យសម្បត្តិជំនួសរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានតម្លៃស្មើនឹងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបង្កក ការឃាត់ទុក និងការរឹបអូស ។

ឃ- **ស្ថាប័នត្រួតពិនិត្យ** គឺជាធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រនិងស្ថាប័នផ្សេងទៀត ដែលត្រួតពិនិត្យលើបុគ្គលរាយការណ៍ ។

ង- **សំអាងនៃបទល្មើស** គឺជាបទល្មើសឧក្រិដ្ឋឬបទល្មើសមជ្ឈិម ទោះជាបានប្រព្រឹត្តនៅក្រៅប្រទេស ដែលផលទទួលបានពីបទល្មើសទាំងនេះអាចក្លាយជាកម្មវត្ថុនៃការសម្អាតប្រាក់ ដូចបានកំណត់នៅក្នុងកថាខណ្ឌ (ក) នៃមាត្រា៣ នៃច្បាប់នេះ ។

ដើម្បីអាចយកមកប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ប្តឹងអំពីការសម្អាតប្រាក់ សំអាងនៃបទល្មើស ដែលត្រូវបានប្រព្រឹត្តនៅក្រៅប្រទេស ត្រូវមានចរិតជាបទល្មើសនៅក្នុងប្រទេស ដែលបទល្មើស នេះត្រូវបានប្រព្រឹត្តនិងស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានកិច្ចព្រមព្រៀងពិសេសផ្សេងពីនេះ ។

សំអាងនៃបទល្មើស មានដូចខាងក្រោម ៖

- ការចូលរួមក្នុងក្រុមឧក្រិដ្ឋជន ដែលមានការចាត់តាំង និងការប្រកបរបរអាជីវកម្មទុច្ចរិត
- ភេរវកម្ម រួមទាំងហិរញ្ញប្បទានភេរវកម្ម
- ការជួញដូរមនុស្សនិងទេសន្តរប្រវេសន៍
- ការជួញដូរផ្លូវភេទ រួមទាំងការជួញដូរផ្លូវភេទលើកុមារ
- ការជួញដូរខុសច្បាប់នូវគ្រឿងញៀនណាកូទិក និងសារធាតុញៀន
- ការជួញដូរអាវុធខុសច្បាប់
- ការជួញដូរខុសច្បាប់នូវទំនិញដែលបានលួច និងទំនិញផ្សេងទៀត
- អំពើពុករលួយនិងសំណូក
- ការបន្លំលួច
- ការក្លែងរូបិយប័ណ្ណ
- ការក្លែងនិងការលួចចម្លងផលិតផល
- បទល្មើសបរិស្ថានឬការកាប់ឈើខុសច្បាប់
- ការធ្វើឃាត ការបង្ករបួសដល់រាងកាយធ្ងន់ធ្ងរ
- ការចាប់ជំរិត ការឃុំខ្លួនខុសច្បាប់ និងចំណាប់ខ្មាំង
- ការប្លន់ឬការលួច
- ការរត់ពន្ធ
- ការគំរាមកំហែង






Ksl

- ការក្លែងបន្លំឯកសារ
- អំពើប្លន់តាមសមុទ្រ
- ការគេចពន្ធ និង
- ការធ្វើជំនួញជារនុកក្នុងនិងការបោកបញ្ឆោតទីផ្សារ ។

ច- **ហិរញ្ញប្បទានភេរវកម្ម** គឺជាការផ្តល់ឬការប្រមូលដោយចេតនានូវសេវាហិរញ្ញវត្ថុឬសេវាផ្សេងទៀត ក្នុងបំណងប្រើប្រាស់សេវានេះឬដោយដឹងថាមូលនិធិនេះនឹងត្រូវបានឬអាចប្រើទាំងមូលឬមួយផ្នែកសម្រាប់គាំទ្រភេរវកម្ម សកម្មភាពរបស់ភេរវករឬអង្គការចាត់តាំងរបស់ភេរវកម្ម ។

ឆ- **ប្រតិបត្តិការសង្ស័យ** គឺជាប្រតិបត្តិការទាក់ទងទៅនឹងមូលនិធិ ដែលត្រូវបានសង្ស័យថាបានមកពីការប្រព្រឹត្តបទល្មើសឬជាមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម ។

ជ- **អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ** គឺជាអង្គការកណ្តាលដែលទទួលខុសត្រូវក្នុងការទទួលវិភាគនិងផ្សព្វផ្សាយរបាយការណ៍ស្តីពីប្រតិបត្តិការសង្ស័យ ដូចបានកំណត់នៅក្នុងកថាខណ្ឌ (ឆ) នៃមាត្រា៣ នៃច្បាប់នេះ ប្រតិបត្តិការសាច់ប្រាក់ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១ នៃមាត្រា១២ នៃច្បាប់នេះ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ។

ឈ-**អត្ថគាហកចុងក្រោយ** គឺជាបុគ្គលដែលកាន់កាប់ឬត្រួតត្រាចុងក្រោយបង្អស់លើអតិថិជន និង/ឬបុគ្គលដែលធ្វើប្រតិបត្តិការជំនួស រាប់បញ្ចូលទាំងបុគ្គលទាំងឡាយដែលកំពុងធ្វើប្រតិបត្តិការ ជាចុងក្រោយលើនីតិបុគ្គលឬកិច្ចសម្របសម្រួលណាមួយ ។

ញ- **បុគ្គលពាក់ព័ន្ធនយោបាយ** គឺជាឯកត្តជនដែលជាឬដែលត្រូវបានប្រគល់មុខងារសាធារណៈខ្ពង់ខ្ពស់នៅក្រៅប្រទេស ដូចជាប្រមុខរដ្ឋឬប្រមុខរដ្ឋាភិបាល អ្នកនយោបាយជាន់ខ្ពស់ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ មន្ត្រីយោធាឬមន្ត្រីយុត្តិធម៌ នាយកប្រតិបត្តិជាន់ខ្ពស់នៃសាជីវកម្មរដ្ឋឬមន្ត្រីគណបក្សសំខាន់ៗ ។

ដ- **ក្រុមហ៊ុនអាណត្តិព្យាបាល** គឺជានីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយបុគ្គលម្នាក់ដែលជាអ្នកប្រគល់អាណត្តិព្យាបាល ។ អ្នកប្រគល់អាណត្តិព្យាបាលផ្ទេរកម្មសិទ្ធិស្របច្បាប់នៃទ្រព្យសម្បត្តិទៅឲ្យអ្នកទទួលអាណត្តិព្យាបាលដែលធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនោះសម្រាប់ជាផលប្រយោជន៍ដល់អត្ថគាហកណាម្នាក់ច្បាស់លាស់ ។

ឋ- **ទុច្ចរិតកម្ម** គឺការធ្វើឲ្យទៅជាមោឃៈ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា ២៩ថ្មី១.- បទសម្អាតប្រាក់

ការសម្អាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤០ ០០០ ០០០ (សែសិបលាន) រៀល រហូតដល់ស្មើ ១០០ ០០០ ០០០ (មួយរយលាន) រៀល ឬរហូតដល់ស្មើនឹងតម្លៃមូលនិធិឬទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់ ។

បទប្បញ្ញត្តិពីមាត្រា៤០៦ (ស្ថានទម្ងន់ទោស) ដល់មាត្រា៤០៨ (ទោសបន្ថែម ៖ ប្រភេទនិងរយៈពេល) នៃក្រមព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌសម្រាប់បទល្មើសសម្អាតប្រាក់ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ទៅ ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី២.- ការបដិសេធផ្តល់ព័ត៌មាន

បុគ្គលណាដែលមានចេតនាមិនផ្តល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងស្ថាប័នត្រួតពិនិត្យដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ថ្ងៃ ដល់១ (មួយ) ខែ និង ផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ដល់១ ០០០ ០០០ (មួយលាន) រៀល ឬ ទោសណាមួយនៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ២ ០០០ ០០០ (ពីរលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែម អនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។



Ksl

## មាត្រា ២៩ថ្មី៣.- ការខកខានមិនបានធ្វើរបាយការណ៍ប្រតិបត្តិការ

បុគ្គលណាដែលមានចេតនាមិនបានរាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ឬប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ដល់ ៥ ០០០ ០០០ (ប្រាំលាន) រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើស ដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ២៩ថ្មី៤.- ការរំលោភកាតព្វកិច្ចផ្តល់ព័ត៌មាននិងការហាមឃាត់ការផ្តល់ព័ត៌មាន

បុគ្គលណាដែលមានកាតព្វកិច្ចផ្តល់ព័ត៌មានឬបញ្ជូនរបាយការណ៍ ដូចមានចែងនៅក្នុងមាត្រា១៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឬបុគ្គលណាដែលបានដឹងរឿងហើយមានចេតនាផ្តល់ព័ត៌មានឬរាយការណ៍ល្មើសនឹងបទប្បញ្ញត្តិនៃការហាមឃាត់ការផ្តល់ព័ត៌មាន ដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ដល់៥ ០០០ ០០០ (ប្រាំលាន) រៀល ឬទោសណាមួយ នៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ២៩ថ្មី៥.- ការរំលោភកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ**

បុគ្គលណាដែលមានចេតនារំលោភកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ដល់ ៥ ០០០ ០០០ (ប្រាំលាន) រៀល ឬទោសណាមួយនៃទោសទាំងពីរ ។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

**មាត្រា ២៩ថ្មី៦.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលត្រូវផ្តន្ទាទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា១៧៤ (ការហាមឃាត់ចំពោះការធ្វើការអំពាវនាវជាសាធារណៈឲ្យធ្វើការសន្សំសំចៃ) នៃក្រមព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Kol

៦- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទដែលកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៧- ការរឹបអូសផលទុននិងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទ ដែលកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹមអូស និងសិទ្ធិតតិយជន) នៃក្រមព្រហ្មទណ្ឌ ។

៨- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៩- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ ។

## មាត្រា ២៩ថ្មី៧.- បទហិរញ្ញប្បទានភេរវកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ ចំពោះបុគ្គលណាដែលមានចេតនាផ្តល់ឬប្រមូលមូលនិធិឬផ្តល់លទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិ ធនធាន ឬសេវាកម្ម ដោយផ្ទាល់ឬដោយប្រយោលសម្រាប់អត្ថប្រយោជន៍របស់ ៖

ក. បុគ្គលណាមួយដែលបានប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តនៅក្នុងច្បាប់ស្តីពីការប្រឆាំង នឹងភេរវកម្មឬបទល្មើសស្របគ្នា ក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ. អង្គភាពដែលជាកម្មសិទ្ធិរបស់ឬដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ដោយបុគ្គលដែលបានបញ្ញត្តនៅក្នុងចំណុច "ក" ខាងលើនេះ ឬ

គ. បុគ្គលឬអង្គភាពដែលធ្វើសកម្មភាពក្នុងនាមឬតាមការបញ្ជារបស់បុគ្គលដែលបានបញ្ញត្តក្នុងចំណុច "ក" ខាងលើនេះ ។

អំពើដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌ១ ខាងលើនេះ គឺជាបទល្មើសទោះបីជាទ្រព្យសម្បត្តិឬធនធានឬសេវាកម្មមិនត្រូវបានយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសដែលមានបញ្ញត្តក្នុងច្បាប់ប្រឆាំងនឹងភេរវកម្មឬបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសក៏ដោយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Kol

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើស ដែលបានប្រព្រឹត្តនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀលទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា២៩ថ្មី៦ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ ។

## មាត្រា ៣០ថ្មី១.- ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល

សមាជិកដែលត្រូវបានចាត់តាំងនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មអាចបង្កកទ្រព្យសម្បត្តិនិងចាត់វិធានការបណ្តោះអាសន្ន សមស្របផ្សេងទៀត កាន់តែឆាប់ដែលអាចធ្វើទៅបាន នៅពេលមានការសង្ស័យឬមានមូលដ្ឋានសមស្របសង្ស័យថាទ្រព្យសម្បត្តិនោះពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើសមុននឹងស្នើសុំសេចក្តីសម្រេចពីតុលាការក្នុងគោលបំណងរក្សាទុកទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសដូចមានចែងនៅក្នុងមាត្រា៣០ថ្មី២ (ការរឹបអូសទ្រព្យសម្បត្តិ) នៃច្បាប់នេះ ។

អាជ្ញាធរអនុវត្តច្បាប់ ក្រោយពេលដឹងថា មានវត្តមាននៃទ្រព្យសម្បត្តិដែលពាក់ព័ន្ធឬសង្ស័យ ថាពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស ត្រូវតែឃាត់ទុកទ្រព្យសម្បត្តិនោះដោយគ្មានបង្អង់ និងយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន ហើយប្តឹងសុំទៅតុលាការដើម្បីបង្កកទ្រព្យសម្បត្តិនោះ ។

## មាត្រា ៣០ថ្មី២.- ការរឹបអូសទ្រព្យសម្បត្តិ

ក្នុងស្ថានភាពមានទោសសម្អាតប្រាក់ឬសំអាងនៃបទល្មើសឬហិរញ្ញប្បទានភេរវកម្ម តុលាការអាចចេញបទបញ្ជាឲ្យរឹបអូស ៖

ក- ទ្រព្យសម្បត្តិដែលជាផលបទល្មើស រួមទាំងទ្រព្យសម្បត្តិរួមបញ្ចូលគ្នាឬត្រូវបានផ្លាស់ប្តូរ ជាមួយផលទាំងនោះ

ខ- ទ្រព្យសម្បត្តិដែលជាចំណូលឬអត្ថប្រយោជន៍ផ្សេងទៀតដែលទទួលបានពីផលនៃបទល្មើស

គ- ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឧក្រិដ្ឋ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឃ- ទ្រព្យសម្បត្តិដែលមានចែងនៅចំណុច (ក) (ខ) និង (គ) នៃមាត្រានេះដែលត្រូវបាន ផ្ទេរទៅភាគីណាមួយ លើកលែងតែមានភស្តុតាងបញ្ជាក់ថាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទទួលបានដោយបានបង់ថ្លៃត្រឹមត្រូវឬសម្រាប់ការផ្តល់សេវាត្រឡប់វិញស្របតាមតម្លៃនៃទ្រព្យសម្បត្តិឬលើមូលដ្ឋានស្របច្បាប់ណាមួយផ្សេងទៀត និងថាបុគ្គលនោះ មិនបានដឹងពីប្រភពមិនស្របច្បាប់នៃទ្រព្យសម្បត្តិនោះឬ

ង- ទ្រព្យសម្បត្តិរបស់ចារីដែលពាក់ព័ន្ធបទល្មើសដែលមានតម្លៃស្មើនឹងតម្លៃនៃផលនៃបទល្មើស ។

ក្នុងករណីតុលាការរកឃើញបទល្មើសមានពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬសំអាងនៃបទល្មើស ឬហិរញ្ញប្បទានភេរវកម្ម ទោះបីជាចារីមិនទាន់ត្រូវបានផ្តន្ទាទោសដោយសារមិនស្គាល់អត្តសញ្ញាណ ឬស្លាប់ តុលាការនៅតែអាចចេញបញ្ជារឹបអូសទ្រព្យសម្បត្តិដែលត្រូវបានឃាត់ទុក ប្រសិនបើមាន ភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ទ្រព្យសម្បត្តិនោះជាផលនៃបទល្មើស ។

បន្ថែមពីការរឹបអូសទ្រព្យសម្បត្តិដែលមានចែងក្នុងចំណុច (ក) (ខ) (គ) (ឃ) និង (ង) នៃមាត្រានេះ ការរឹបអូសទ្រព្យសម្បត្តិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានអនុវត្តផងដែរ ។

## មាត្រា ៣០ថ្មី៣.- ទ្រព្យសម្បត្តិបញ្ចូលគ្នា

នៅពេលណាដែលទ្រព្យសម្បត្តិដែលជាឬត្រូវបានសង្ស័យដោយសមហេតុផលថាជាទ្រព្យសម្បត្តិដែលទាក់ទងនឹងបទល្មើសឬជាផលនៃបទល្មើស ត្រូវបានដាក់បញ្ចូលជាមួយទ្រព្យសម្បត្តិដទៃទៀតដែលមិនទាក់ទងនឹងបទល្មើសឬផលនៃបទល្មើស ត្រូវបានរឹបអូសតាមបញ្ញត្តិ មាត្រា៣០ថ្មី១ (ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល) ឬមាត្រា៣០ថ្មី២ (ការរឹបអូសទ្រព្យសម្បត្តិ) នៃច្បាប់នេះ ត្រូវតែមិនលើសតម្លៃនៃទ្រព្យសម្បត្តិដែលជាឬត្រូវបានសង្ស័យ ដោយសមហេតុផលថាជាទ្រព្យសម្បត្តិទាក់ទងនឹងបទល្មើសឬផលនៃបទល្មើស ។

## មាត្រា ៣០ថ្មី៤.- បន្ទុករបស់ជនជំទាស់នឹងសេចក្តីសម្រេច

ជនដែលជំទាស់នឹងសេចក្តីសម្រេចតាមបញ្ញត្តិមាត្រា៣០ថ្មី១ (ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល) ឬមាត្រា៣០ថ្មី២ (ការរឹបអូសទ្រព្យសម្បត្តិ) ខាងលើនេះ ដែល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សុំដកទ្រព្យសម្បត្តិដែលត្រូវបានសម្រេចឲ្យដក ឬរឹបអូសឬដែលសុំបដិសេធសេចក្តីសម្រេចនេះត្រូវតែបង្ហាញតុលាការថា ជននោះមានសិទ្ធិដោយត្រឹមត្រូវលើទ្រព្យសម្បត្តិនោះ ហើយទ្រព្យសម្បត្តិនោះមិនជាប់ពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស ។

**មាត្រា ៣០ថ្មី៥.- ការបង្កកមូលនិធិពាក់ពន្ធ័នឹងហិរញ្ញប្បទានភេរវកម្ម**

ទោះបីមានបទប្បញ្ញត្តិច្បាប់ផ្សេងទៀតក៏ដោយ មូលនិធិរបស់ភេរវករបស់អ្នកផ្តល់ហិរញ្ញប្បទានភេរវកម្មនិងរបស់អង្គការភេរវកម្មដែលកំណត់ដោយសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧ និងលេខ១៣៧៣ និងសេចក្តីសម្រេចចិត្តបន្តបន្ទាប់ ត្រូវបានបង្កកដោយគ្មានពន្យារពេលតាមយន្តការនិងនីតិវិធីដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ព្រស.១៣០៦.៥៧៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ហត្ថលេខា**

**ជា ចាន់តូ** លេខៈ ៥៦៧ស.ណ

**សំណៅដែលមានសេចក្តីថ្លែងការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការបង្ការ និងការពន្លត់អគ្គិភ័យ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការបង្ការនិងការពន្លត់អគ្គិភ័យ សំដៅការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការទទួលខុសត្រូវរបស់ជនគ្រប់រូប និងអំពីលក្ខខណ្ឌវិធានការនានាដើម្បីបង្ការនិងពន្លត់អគ្គិភ័យ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចខាងក្រោម ៖

- **អគ្គិភ័យ** សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន ។
- **ការបង្ការអគ្គិភ័យ** សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាព មិនឲ្យមានអគ្គិភ័យកើតឡើង ។
- **ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ** សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុងនិង/ឬក្រៅគោលដៅ និងវិធានការនានាដើម្បីបង្ការទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ ។
- **មធ្យោបាយ** សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការនិងពន្លត់អគ្គិភ័យ ។
- **ទីកន្លែងងាយឆេះឬងាយផ្ទុះឆេះ** សំដៅដល់ទីកន្លែងដែលមានស្តុក ប្រើប្រាស់សារធាតុងាយឆេះឬងាយផ្ទុះឆេះ ។
- **សារធាតុងាយឆេះឬងាយផ្ទុះឆេះ** សំដៅដល់សារធាតុរាវ រឹង ឧស្ម័ន គីមី ទំនិញ ឬវត្ថុធាតុដើមដែលងាយឆេះឬងាយផ្ទុះឆេះ ។
- **ការពន្លត់អគ្គិភ័យ** សំដៅដល់ការពន្លត់អគ្គិភ័យនិងទប់ស្កាត់ការឆេះរាលដាលដោយប្រើប្រាស់កម្លាំង ប្រើប្រាស់មធ្យោបាយពន្លត់អគ្គិភ័យ និងប្រើប្រាស់គ្រប់វិធានការផ្សេងៗទៀត ។

- តំបន់ពន្លត់អគ្គិភ័យ សំដៅដល់ទីកន្លែងកំពុងឆេះឬប្រឡយមនឹងការឆេះដែលសមត្ថកិច្ចកំពុងប្រតិបត្តិការពន្លត់អគ្គិភ័យ ។
- គោលដៅ សំដៅដល់ទីកន្លែងនានានិងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង ។

**មាត្រា ៥.-**

រាល់អំពើដែលអាចបង្កឲ្យមានអគ្គិភ័យកើតឡើងត្រូវហាមឃាត់ ។

**មាត្រា ៦.-**

ជនគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានករណីយកិច្ចចូលរួមក្នុងសកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ។

## ជំពូកទី ២
## សមត្ថកិច្ច

**មាត្រា ៧.-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការស្នើនិងដាក់ចេញនូវគោលការណ៍ វិធានការ ការបណ្តុះបណ្តាល ការហ្វឹកហាត់ជំនាញអំពីការបង្ការនិងការពន្លត់អគ្គិភ័យ ។

**មាត្រា ៨.-**

អ្នកទទួលខុសត្រូវតាមគោលដៅនានា ត្រូវទទួលខុសត្រូវដោយផ្ទាល់ក្នុងកិច្ចប្រតិបត្តិការបង្ការនិងពន្លត់អគ្គិភ័យ ។

អង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ត្រូវឆ្លើយតបតាមសំណើឬអន្តរាគមន៍ជាបន្ទាន់ដល់គ្រប់គោលដៅដែលមានអគ្គិភ័យកើតឡើង ។

លក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យតាមគោលដៅ និងការបង្ការអគ្គិភ័យនៅតាមលំនៅឋានរបស់ជនគ្រប់រូប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៩.-**

កិច្ចប្រតិបត្តិការបង្ការនិងពន្លត់អគ្គិភ័យ ការត្រួតពិនិត្យ ការបញ្ជាក់ទទួលស្គាល់ប្រព័ន្ធបង្ការអគ្គិភ័យលើគោលដៅ ការផ្អាកសកម្មភាពបណ្តោះអាសន្នដល់គោលដៅ ឬសកម្មភាពណាដែលខ្វះលក្ខខណ្ឌនិងវិធានការបង្ការនិងពន្លត់អគ្គិភ័យ ការពិនិត្យអង្កេតកន្លែងកើតហេតុ ការធ្វើកោសល្យវិច័យ ចំពោះជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ ។

| | | | |
|---|---|---|---|
| ១៧២- | លោក | ហួត លុច | នាយរងខណ្ឌរដ្ឋបាលជលផលកំពង់ធំ នៃរដ្ឋបាលជលផល |
| ១៧៣- | លោក | អ៊ិន ចាន់ធី | នាយខណ្ឌរដ្ឋបាលជលផលឧត្តរមានជ័យ នៃរដ្ឋបាលជលផល |
| ១៧៤- | លោក | ឡុញ វុទ្ធី | នាយរងខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ នៃរដ្ឋបាលជលផល |
| ១៧៥- | លោក | មិត្រ សុខសុភ័ក្រ | នាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ នៃរដ្ឋបាលជលផល |
| ១៧៦- | លោក | ពុត ស៊ុនលី | នាយរងផ្នែករដ្ឋបាលជលផលក្រគរ នៃខណ្ឌ.ពោធិ៍សាត់ នៃរដ្ឋបាលជលផល |
| ១៧៧- | លោក | ហៀន វាចារ | នាយខណ្ឌរដ្ឋបាលជលផលកំពង់ស្ពឺ នៃរដ្ឋបាលជលផល |
| ១៧៨- | លោក | កៅ មុនីរិទ្ធ | នាយរងអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ នៃរដ្ឋបាលជលផល |
| ១៧៩- | លោក | អ៊ិត ស៊ាងសុរិមល | នាយរងខណ្ឌរដ្ឋបាលជលផលកោះកុង នៃរដ្ឋបាលជលផល |
| ១៨០- | លោក | សេង ប៊ុណ្ណា | មន្ត្រីខណ្ឌរដ្ឋបាលជលផលកោះកុង នៃរដ្ឋបាលជលផល |
| ១៨១- | លោកស្រី | ស៊ីង សាលីនីន | អនុ.ការិ.រដ្ឋបាលនិងតាមដានការអនុវត្ត នៃរដ្ឋបាលជលផល |
| ១៨២- | កញ្ញា | ផាន់ សុគា | អនុ.ការិ.អភិវឌ្ឍជីវភាពសហគមន៍ នៃរដ្ឋបាលជលផល |
| ១៨៣- | លោក | ណែម កាណូ | អនុ.ការិ.អភិវឌ្ឍជីវភាពសហគមន៍ នៃរដ្ឋបាលជលផល |
| ១៨៤- | លោក | នេត ឈុនអ៊ាម | អនុ.ការិ.នីតិកម្ម នៃរដ្ឋបាលជលផល |
| ១៨៥- | លោក | សេង សារឿន | មន្ត្រីរដ្ឋបាលជលផល |
| ១៨៦- | លោក | ស្វាយ ជឿន | មន្ត្រីរដ្ឋបាលជលផល |
| ១៨៧- | លោក | សាម ខែម | មន្ត្រីរដ្ឋបាលជលផល |
| ១៨៨- | លោក | ស្រី សុវណ្ណនី | មន្ត្រីរដ្ឋបាលជលផល |
| ១៨៩- | លោក | កែវ រ័ត្ន | មន្ត្រីរដ្ឋបាលជលផល |
| ១៩០- | លោក | ឡុញ ចាន់ដារ៉ា | មន្ត្រីរដ្ឋបាលជលផល |
| ១៩១- | លោក | ព្រំ សារិទ្ធ | មន្ត្រីរដ្ឋបាលជលផល |
| ១៩២- | លោក | គត់ គីលាភ | មន្ត្រីរដ្ឋបាលជលផល |
| ១៩៣- | លោក | អ៊ិច វ៉ាន់ណេត | មន្ត្រីអគ្គនាយកដ្ឋានកៅស៊ូ |
| ១៩៤- | លោក | ង៉ែត ធារ៉ា | អនុប្រធានមន្ទីរកសិកម្ម ខេត្តរតនគិរី |
| ១៩៥- | លោក | ចក់ ស៊ីគៀង | អនុប្រធានការិ.រដ្ឋបាល មន្ទីរកសិកម្មខេត្តរតនគិរី |
| ១៩៦- | លោក | ញឹម គឹមជាង | អនុប្រធានការិ.បសុព្យាបាល មន្ទីរកសិកម្មខេត្តរតនគិរី |
| ១៩៧- | លោក | សៅ ស៊ុនថៃ | អនុប្រធានការិ.គណនេយ្យ មន្ទីរកសិកម្មខេត្តរតនគិរី |
| ១៩៨- | លោក | ជុំ ចន្ទ័ថុល | ប្រធានការិ.ផ្សព្វផ្សាយកសិកម្ម មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ១៩៩- | លោក | សុខ អាង | អនុប្រធានការិ.ផែនការ-គណនេយ្យ មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ២០០- | លោក | ជា សុខលី | ប្រធានការិ.ក្សេត្រសាស្ត្រ មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ២០១- | លោក | ប៊ុន សុវណ្ណនី | ប្រធានការិ.ផលិត.បសុព្យាបាល មន្ទីរកសិកម្មខេត្តព្រះសីហនុ |
| ២០២- | លោក | អ៊ឹង សំអុល | ប្រធានការិ. មន្ទីរកសិកម្មខេត្តព្រះសីហនុ |

**មាត្រា ១៦.-**

ការដាក់លក់រាយប្រេងឥន្ធនៈឬឧស្ម័នចំហេះរបស់ប្រជាពលរដ្ឋ ដើម្បីបម្រើជីវភាពប្រចាំថ្ងៃ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានា ស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៧.-**

គោលដៅស្តុក ផលិតកែច្នៃប្រេងឥន្ធនៈ កែច្នៃសារធាតុងាយឆេះឬងាយផ្ទុះឆេះ ត្រូវស្ថិតនៅទីតាំងដែលធានាមិនបង្កហានិភ័យដល់ទីប្រជុំជន។ ចំពោះគោលដៅទាំងឡាយណាដែលមានការអនុញ្ញាតរួចហើយ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៨.-**

គ្រប់ទីប្រជុំជនត្រូវមានប្លង់គោលតម្កល់ទុកនៅអង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ។

រាល់សំណង់ត្រូវធានាឲ្យមានប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យមុនដំណើរការសាងសង់ ។

ចំណាត់ថ្នាក់សំណង់និងគោលដៅ ដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

**មាត្រា ១៩.-**

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ដល់គោលដៅត្រូវធ្វើឡើងសម្រាប់រយៈពេល ២ឆ្នាំម្តង ។ ក្នុងករណីចាំបាច់ ម្ចាស់គោលដៅអាចលើកសំណើសុំឲ្យត្រួតពិនិត្យមុនកាលកំណត់បាន ។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យ ការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២០.-**

នៅគ្រប់ការរៀបចំពិធីធំៗដែលប្រមូលផ្តុំមនុស្សច្រើនកុះករ អ្នករៀបចំ ឬអ្នកគ្រប់គ្រង ឬអ្នកទទួលខុសត្រូវពិធី ត្រូវសហការជាមួយអង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ដើម្បីធ្វើផែនការបង្ការពន្លត់អគ្គិភ័យនិងជម្លៀសមនុស្សចេញក្នុងករណីមានអគ្គិភ័យកើតឡើង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៤
## ការពន្លត់អគ្គិភ័យ

**មាត្រា ២១.-**

ក្នុងករណីមានអគ្គិភ័យកើតឡើង មន្ត្រីបញ្ជាដឹកនាំនគរបាលពន្លត់អគ្គិភ័យមានសិទ្ធិ ៖
- កំណត់តំបន់ប្រតិបត្តិការពន្លត់អគ្គិភ័យនិងតំបន់ហាមឃាត់ការចេញចូលឆ្លងកាត់ និងសហការការពារ សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- ប្រមូលកម្លាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង និងមធ្យោបាយនានាដើម្បីជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងជួយពន្លត់អគ្គិភ័យ ។

**មាត្រា ២២.-**

នៅពេលដែលមានអគ្គិភ័យកើតឡើង មន្ត្រីដឹកនាំនគរបាលប្រតិបត្តិការពន្លត់អគ្គិភ័យត្រូវចាត់វិធានការគ្រប់បែបយ៉ាងដើម្បីពន្លត់អគ្គិភ័យ សំដៅជួយសង្គ្រោះជីវិតមនុស្សនិងទ្រព្យសម្បត្តិជាបន្ទាន់ ។

**មាត្រា ២៣.-**

ជនណាដែលបានដឹងព័ត៌មានអំពីអគ្គិភ័យឬបានឃើញអគ្គិភ័យកើតឡើងឬបម្រុងនឹងកើតឡើង ត្រូវផ្តល់ដំណឹងជាបន្ទាន់ដល់សមត្ថកិច្ចឬនគរបាលបង្ការនិងពន្លត់អគ្គិភ័យដែលនៅជិតបំផុត ដើម្បីចាត់វិធានការដោះស្រាយឲ្យបានទាន់ពេលវេលា ។

នៅពេលដែលមានអគ្គិភ័យកើតឡើង ហើយពុំទាន់មានវត្តមាននគរបាលបង្ការនិងពន្លត់អគ្គិភ័យ អ្នកទទួលខុសត្រូវតាមគោលដៅឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងពន្លត់អគ្គិភ័យ ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានានៅពេលទទួលបានសំណូមពរសុំជួយអន្តរាគមន៍ ត្រូវឆ្លើយតបជាបន្ទាន់ ។

## ជំពូកទី ៥
## ការគាំពារ

**មាត្រា ២៤.-**

ចំពោះភ្នាក់ងារនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ឬជនណាដែលពលីជីវិតឬរងរបួស ប៉ះពាល់សុខភាព ឬពិការមួយជីវិតក្នុងពេលប្រតិបត្តិការពន្លត់អគ្គិភ័យ រដ្ឋត្រូវទទួលខុសត្រូវដោះស្រាយគោលនយោបាយ ផ្តល់កិត្តិយស និងផ្តល់ការព្យាបាលដោយឥតគិតថ្លៃ ។

ការផ្តល់សំណងនៃការខូចខាតទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា ២១ និងមាត្រា ២២ នៃច្បាប់នេះជាបន្ទុករបស់រដ្ឋ ។

**មាត្រា ២៥.-**

រដ្ឋទទួលខុសត្រូវដោះស្រាយទីកន្លែង ជម្រកស្នាក់នៅបណ្តោះអាសន្ន និងដោះស្រាយជីវភាព សង្គមដល់ជនរងគ្រោះដោយសារអគ្គិភ័យ ។

**មាត្រា ២៦.-**

រដ្ឋលើកទឹកចិត្តសប្បុរសជន អង្គការជាតិ អង្គការអន្តរជាតិក្នុងការជួយឧបត្ថម្ភ សង្គ្រោះដល់ជន រងគ្រោះដោយសារអគ្គិភ័យ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

មន្ត្រីសមត្ថកិច្ចអគ្គិភ័យដែលខ្វះការទទួលខុសត្រូវ មិនបំពេញភារកិច្ច ឬបំពេញភារកិច្ចដោយ មិនត្រឹមត្រូវក្នុងការពន្លត់អគ្គិភ័យ បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ អ្នកដទៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ 000 000 (មួយលាន) រៀល ទៅ ៤ 000 000 (បួនលាន) រៀល ។

**មាត្រា ២៨.-**

អំពើរារាំង បង្កឧបសគ្គដោយចេតនា ដល់សកម្មភាពពន្លត់អគ្គិភ័យ បង្កឲ្យមានការខូចខាត ធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជា ប្រាក់ពី ៤ 000 000 (បួនលាន) រៀល ទៅ ១០ 000 000 (ដប់លាន) រៀល ។

**មាត្រា ២៩.-**

អំពើផ្តល់ព័ត៌មានក្លែងឬអំពើបើកកកាយព័ត៌មានក្លែង ដើម្បីធ្វើឲ្យជឿថាអគ្គិភ័យនឹងកើតមាន ឬអគ្គិភ័យបានកើតមានឡើង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និង ពិន័យជាប្រាក់ពី ២ 000 000 (ពីរលាន) រៀល ទៅ ៤ 000 000 (បួនលាន) រៀល ។

**មាត្រា ៣០.-**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុង មាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះអំពើបំផ្លិច បំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអ្នកដទៃដោយអានុភាពនៃ អគ្គិភ័យ កាលបើអំពើនេះបណ្តាលមកពី ៖



Ksl

១- ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ។

២- ការរំលោភបំពានលើកាតព្វកិច្ចសន្តិសុខឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចមានចែងក្នុងមាត្រា ២០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣១.-**

ក្រៅពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ អំពើដែលជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៣២.-**

បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨ និងពីមាត្រា ១៤ ដល់មាត្រា ១៩ ត្រូវចាប់អនុវត្តក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយពេលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ចាស.១៣០៦.៥៧៩

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង លេខៈ ៤៦៦ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៤១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **អ៊ឹង ជុនហួរ** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៤៨៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

**សយ សុខា**

៣៧៧-១៣០៥-៥៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ឆេប ឆែម** ជាទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៨៧-១៣០៥-៥៤៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៣

លេខៈ ៤៩៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ .ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ សប្បុរសជនជាតិ និងអន្តរជាតិ ចំនួន ២១រូប
ដែលមានគុណបំណាច់យ៉ាងធំធេង ក្នុងការបម្រើជាតិមាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស ជាតូបការ :

១- ឧកញ៉ា សៀ ឫទ្ធី

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម លី សុខគីម
២- វរសេនីយ៍ឯក សៀ គូនី អត្តលេខ ០៣៦៤៣០
៣- Mr. Tan Teck Kee
៤- Mr. Ching Chiat Kwong
៥- Mr. Seah Hock Thiam
៦- លោក គីម ចេស្តា
៧- លោក ចិន្តា បណ្ឌិត
៨- លោក ទ្រី ស្រ៊ាង
៩- វរសេនីយ៍ទោ ឌី សុជាតិ អត្តលេខ ០២៤៦១៨

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តមវេជ្ជបណ្ឌិត តែង ចណ្ណៈ

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- វរសេនីយ៍ត្រី ឈុន ផេង អត្តលេខ ០៣១៣៦
២- អនុសេនីយ៍ទោ គ្រី រ៉ាឌី អត្តលេខ ៦៧៦៩៤
៣- លោក អ៊ុត រស់

ង- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

១- ឯកឧត្តមវេជ្ជបណ្ឌិត ម៉ា សាធុធ
២- លោកវេជ្ជបណ្ឌិត ថៃ សុផាន់ណា

ច- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោកវេជ្ជបណ្ឌិត តាំង ហុកសេង

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោកស្រី ហេង វីម៉ាន់
២- លោកស្រី ប៉ាន់ មករា
៣- លោក តា ចចនា
៤- លោក ហុន ចន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៣.១៣០៥.៥២៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣

លេខៈ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៣/៥២៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

